# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១ សរណន

## សារាចរណែនាំ
## ស្តីពី
## ការបញ្ជូនគណៈប្រតិភូទៅបំពេញបេសកកម្មនៅបរទេស

កន្លងមករាជរដ្ឋាភិបាលបានសង្កេតឃើញថា គ្រប់ក្រសួង ស្ថាប័ន បានដំណើរការចូលរួមអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលយ៉ាងមមាញឹក ក្នុងនោះមានការបញ្ជូនគណៈប្រតិភូ ទៅបំពេញទស្សនកិច្ច ចូលរួមសន្និសីទ កិច្ចប្រជុំអន្តរជាតិនានានៅបរទេសជាបន្តបន្ទាប់ ។ ប៉ុន្តែមានក្រសួង ស្ថាប័នមួយចំនួន បានបញ្ជូនគណៈប្រតិភូទៅបំពេញបេសកកម្ម នៅបរទេស ពុំបានជូនពត៌មានឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាងស្ថានទូតកម្ពុជា ប្រចាំនៅបរទេសចូលរួមនៅក្នុងសកម្មភាពជាមួយគណៈប្រតិភូ ដើម្បីសំរបសំរួល និងតាមដានរាល់កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយបណ្តាប្រទេសទាំងនោះនៅឡើយ ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលសូមណែនាំ ដល់គ្រប់ក្រសួង ស្ថាប័នថា ចាប់ពីពេលនេះតទៅ សូមឱ្យគ្រប់ក្រសួង ស្ថាប័នរដ្ឋ ដែលបញ្ជូនគណៈប្រតិភូទៅបំពេញបេសកកម្ម នៅបរទេស ត្រូវផ្តល់ពត៌មានជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិឱ្យបានមុន ដើម្បីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានលទ្ធភាពជូនដំណឹងឬចាត់ឱ្យស្ថានទូតកម្ពុជា ជួយសំរួលបេសកកម្មរបស់គណៈប្រតិភូផង និងចូលរួមក្នុងសកម្មភាពនានារបស់គណៈប្រតិភូផង ។ ក្រោយពេលបំពេញបេសកកម្ម គណៈប្រតិភូគ្រប់ក្រសួង ស្ថាប័នរដ្ឋ ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានលទ្ធភាពបន្តតាមដានការងារទាំងនោះជាបន្តទៀត ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចាត់ឯកអគ្គរាជទូត ឬតំណាងស្ថានទូតឱ្យចូលរួមទៅតាមកំរិតគណៈប្រតិភូនិមួយៗ។

ចំពោះរាល់ទស្សនកិច្ចនៅបរទេស របស់ថ្នាក់ដឹកនាំនៃគ្រប់ក្រសួង ស្ថាប័ន ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ ត្រូវសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលជាមុនសិន ។

ទទួលបានសារាចរណែនាំនេះ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះឱ្យបានសំរេចលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង និងស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ